ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការនិងសាសនា
លេខ: ២៧/២៥ ក.ធ.ស សណន

# សេចក្ដីណែនាំ
# ស្ដីពី
# លក្ខខណ្ឌនៃការប្រឡងវិញ្ញាបនបត្រធម្មវិន័យ ត្រី ទោ ឯក
# នៅថ្ងៃអាទិត្យ ៧កើត ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
# ត្រូវនឹងថ្ងៃទី៥ ខែមករា ឆ្នាំ២០២៥

ដើម្បីឱ្យដំណើរការនៃការប្រឡងវិញ្ញាបនបត្រធម្មវិន័យ **ត្រី ទោ ឯក** ប្រព្រឹត្តទៅដោយជោគជ័យ បេក្ខសមណៈ បេក្ខជនទាំងអស់ ត្រូវគោរពតាមគោលការណ៍មួយចំនួនដូចខាងក្រោម ៖

១- ត្រូវនិមន្ត និងអញ្ជើញមកដល់មណ្ឌលប្រឡង មុនដំណើរការនៃការប្រឡងឱ្យបានយ៉ាងតិច៣០នាទី, គណៈកម្មការប្រឡងពុំអនុញ្ញាតឱ្យបេក្ខសមណៈ បេក្ខជន រូបណាមួយចូលបន្ទប់ប្រឡងក្រោយពេលស្នូរជួងលើកទីពីរឡើយ ។

២- ត្រូវឃ្លុំ ឬគ្រងចីវរឱ្យមានបរិមណ្ឌលល្អ ចំណែកគ្រហស្ថ ស្លៀកសម្លៀកបំពាក់ឯកសណ្ឋានជាសិស្សសាលា ។

៣- ត្រូវភ្ជាប់មកជាមួយនូវសលាកបត្រឯកត្តជន ដែលមានបិទរូបថត ៤ គុណនឹង ៦ ចំនួន មួយសន្លឹកតាមលក្ខខណ្ឌនៃការប្រឡង ករណីបាត់បង់ ឬភ្លេចយកតាមខ្លួន ត្រូវរាយការណ៍ជូនគណៈកម្មការប្រឡងជាបន្ទាន់ ។

៤- បេក្ខសមណៈ បេក្ខជន ត្រូវបានអនុញ្ញាតឱ្យយកសម្ភារប្រើប្រាស់មួយចំនួន ដូចជា ប៊ិកពណ៌ខៀវ ខ្មៅដៃ បន្ទាត់ និងក្រដាស ស ស្អាតចូលក្នុងបន្ទប់ប្រឡង ក្រៅពីនោះដូចជា ថង់យាម ទូរស័ព្ទដៃ ព្រមទាំងសំណៅឯកសារពាក់ព័ន្ធផ្សេងៗ មិនអនុញ្ញាតឱ្យយកចូលក្នុងបន្ទប់ប្រឡងឡើយ ។

៥- ត្រូវរក្សាភាពស្ងៀមស្ងាត់ក្នុងពេលធ្វើកិច្ចការប្រឡង ហើយមិនត្រូវប្រឆាំងតវ៉ាដោយ ពាក្យសម្ដីអសុរោះទៅកាន់គណៈកម្មការត្រួតពិនិត្យ ដែលដកហូតសម្ភារ ឬសំណៅឯកសារណាមួយ ផ្ទុយពីលក្ខខណ្ឌនៃការប្រឡងជាដាច់ខាត ។

៦- រាល់ចម្លើយលើក្រដាសការិយកិច្ច មិនត្រូវលុបដោយទឹក ស ឬធ្វើស្លាកសញ្ញាណាមួយ ជាគ្រឿងសម្គាល់ឡើយ ពុំនោះទេ បេក្ខសមណៈ បេក្ខជនត្រូវបានពិន្ទុសូន្យ ។

៧- ករណីសរសេរកខ្វក់ ឬធ្វើខុសទាំងស្រុងលើទំព័រក្រដាសការិយកិច្ច គណៈកម្មការប្រឡង អនុញ្ញាតឱ្យដូរបានតែមួយដងគត់ ។

៨- បេក្ខសមណៈ បេក្ខជន ត្រូវគង់ ឬអង្គុយតាមលេខតុរបស់ខ្លួន រួចបំពេញកិច្ចការលើក្រដាសការិយកិច្ចឱ្យបានត្រឹមត្រូវ ពេលប្រឡងចប់មុខវិជ្ជានីមួយៗ តាមកាលបរិច្ឆេទ ត្រូវប្រគល់សន្លឹកកិច្ចការនោះជូនអនុរក្សវិញ ។

៩- ក្រោយពេលធ្វើកិច្ចការចប់សព្វគ្រប់រួចរាល់មុនម៉ោងតាមមុខវិជ្ជានៃវិញ្ញាសានីមួយ ៗ បេក្ខសមណៈ បេក្ខជន ត្រូវចេញក្រៅបន្ទប់ប្រឡង ដើម្បីសម្រួលឥរិយាបថធម្មតា មិនអនុញ្ញាតឱ្យនៅរារែក អល់អែក ឡូឡាក្នុងបន្ទប់ប្រឡង ធ្វើឱ្យរំខានដល់បេក្ខសមណៈ បេក្ខជនដទៃឡើយ ។

❖ បេក្ខសមណៈ បេក្ខជន ត្រូវអនុវត្តតាមសេចក្តីណែនាំខាងលើឱ្យបានខ្ជាប់ខ្ជួន ដើម្បីរក្សាគុណតម្លៃក៏ដូចជារបៀបរៀបរយ និងសណ្តាប់ធ្នាប់ល្អ ក្នុងកំលុងពេលនៃការប្រឡងនេះ ។

ថ្ងៃព្រហស្បតិ៍ ៤កើត ខែ មិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ២០២៤

**រដ្ឋមន្ត្រី**

ចាយ_បូរិន